មូលនិធិខ្មែរសម្រាប់ការសិក្សា
CAMBODIAN EDUCATION EXCELLENCE FOUNDATION
634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

# ពាក្យសុំអាហារូបករណ៍

## សេចក្តីណែនាំ ក្នុងការបំពេញ ពាក្យសុំអាហារូបករណ៍ និងតម្រូវការឯកសារផ្សេងៗ

អ្នកអាចទាញយក **ពាក្យសុំអាហារូបករណ៍** អំពី website នេះ: www.ceefoundation.org ហើយសូមរកមើលពាក្យ Programs បន្ទាប់មកសូមរកមើលនៅក្នុងពាក្យ Scholarship ដើម្បីឲ្យបានទៅដល់ **ពាក្យសុំអាហារូបករណ៍** Application នោះ ។
អ្នកក៏អាចទាញយក **ពាក្យសុំអាហារូបករណ៍** អំពី website ខាងលើនេះបានដែរ ដោយរកមើលពាក្យ Publications រួចហើយរកមើលពាក្យ Forms។

## ភាគទី១. សេចក្តីណែនាំក្នុងការផ្ញើតាម e-mail នូវពាក្យសុំអាហារូបករណ៍

សូមបំពេញពាក្យសុំនេះ ដោយប្រិតប្រៀន ដើម្បីជួយសម្រួលដំណើរការពិនិត្យពាក្យសុំរបស់អ្នកឲ្យបានឆាប់រហ័ស ។ សូមសរសេរជាអក្សរពុម្ព ឬសរសេរឲ្យបានច្បាស់ ឲ្យស្រួលអាន ។ សូមបំពេញឲ្យបានពេញលេញ ដោយកុំទុកឲ្យមានសល់ចន្លោះទំនេរក្នុងប្រអប់គូសក្បៀសនៃសំនួរនិមួយៗឲ្យសោះ ។ ធ្វើយ៉ាងនេះ ដើម្បីជៀសវាង កុំឲ្យគណៈកម្មាធិការជ្រើសរើស វិនិច្ឆ័យដោយច្រឡំ បណ្តាលឲ្យអ្នកមិនមានគុណសម្បត្តិគ្រប់គ្រាន់ មិនអាចនឹងទទួលនូវអាហារូបករណ៍យើងបាន។

ត្រូវបំពេញពាក្យសុំ ឲ្យបានចប់សព្វគ្រប់ ឥតចន្លោះ សរសេរឲ្យច្បាស់ អាចងាយអានបាន រួចភ្ជាប់មកជាមួយ នូវឯកសារទាំងអស់ ដែលយើងតម្រូវឲ្យធ្វើ ។ រួចរក្សាទុក Save ឯកសារទាំងអស់នោះទុកនៅក្នុងហ្វាល File pdf តែ១គត់ ហើយត្រូវឲ្យឈ្មោះហ្វាលនោះផង ដូចជានាមឈ្មោះពេញរបស់អ្នក Your full name ប្រភេទពាក្យសុំនោះ Type of application សរសេរឈ្មោះសាលារៀនរបស់អ្នកជាអក្សរកាត់ Your school acronym ចំនួនឆ្នាំសិក្សា Number Years in school.pdf។ **ឧទាហរណ៍ :** បើសិនអ្នកជាឈ្មោះ **ណុប នួន** នឹងជាអ្នកទើបតែដាក់ពាក្យសុំអាហារូបករណ៍ថ្មី ហើយកំពុងតែសិក្សានៅ **វិទ្យាស្ថានបច្ចេកទេសកម្ពុជា** ITC **រៀនឆ្នាំទី២** អ្នកត្រូវសរសេរដូចនេះ **ណុប នួន – សិស្សថ្មី – ITC 2.pdf**

ជាភាសាអង់គ្លេសវិញ ត្រូវសរសេរដូចនេះ NOP Nuon – New – ITC 2 . pdf

មូលនិធិខ្មែរសម្រាប់ការសិក្សា(**មខស**) នឹងមិនព្រមទទួលនូវហ្វាលfileណា ដែលបញ្ជូនមកឲ្យយើងលើសពី១ទេ ហើយហ្វាល File នោះត្រូវតែជាហ្វាល File PDFជាដាច់ខាត ហើយត្រូវផ្ញើហ្វាល File ទាំងអស់នោះមកជារួម ធ្វើជាឯកសារភ្ជាប់**Attachment**តែមួយ ហើយផ្ញើមកតាមអ៊ីម៉ែល(e-mail)យើងនេះ Selecting@ceefoundation.org ហើយសូមបញ្ចូលការពិពណ៌នាអំពីប្រធានបទ Subject នោះផង (Brief description in the **subject** line) ដូចនេះ: subject : Scholarship Application: PEL Chhany– Renewal – RUPP –Year 3 ដែលមានន័យជាខ្មែរដូចតទៅ

subject : **ពាក្យសុំអាហារូបករណ៍ :** **ឈ្មោះប៉ែលចាន់នី – សុំសារជាថ្មី – រៀននូវសាលា RUPP – ឆ្នាំទី៣**

***ចំណុចសំខាន់ត្រូវចងចាំ***: បើបានផ្ញើសំណុំពាក្យសុំ ឬក៏ ឯកសារទាំងអស់នោះមកហើយ មានខ្វះចន្លោះ ឬក៏បំពេញមិនបានសព្វគ្រប់ទេ ឬក៏ផ្ញើមកមិនទាន់ថ្ងៃកំណត់របស់យើងទេ ឬក៏ ខកខានមិនបានអនុលោមទៅតាមការណែនាំនេះទេ សំណុំពាក្យសុំនោះ នឹងទុកជាមោឃៈភ្លាម ។

634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

## ភាគទី២. **ឯកសារគាំទ្រ** Support Letters **ពាក្យសុំអាហារូបករណ៍**

អ្នកត្រូវតែយល់ព្រមផ្តល់នូវឯកសារទាំងអស់ ជាមួយនឹង **ពាក្យសុំអាហារូបករណ៍** ដែលអ្នកបានបំពេញមកឲ្យ មខស ដើម្បីអាចឲ្យយើងយកសំណុំពាក្យសុំនោះមកពិនិត្យមើល អាស្រ័យទៅតាមប្រភេទពាក្យសុំអាហារូបករណ៍នោះ ជាសិស្សថ្មី ឬ សុំសារជាថ្មី។ ការខ្វះខាតឯកសារណាមួយ នឹងនាំឲ្យមានការយឺតយូរ ឬមានការបដិសេធន៍នូវការផ្តល់ជូនអាហារូបករណ៍ដល់អ្នក។ ឯកសារទាំងអស់នោះមានដូចតទៅ គឺៈ

១) រូបថត ទំហំ ៤០មម X ៦០មម ឬទំហំស្រដៀងនេះ ជារូបពណ៌ធម្មជាតិ ឬជារូបថតស-ខ្មៅ ។

២) សញ្ញាប័ត្រមធ្យមសិក្សា High School Diploma បើអ្នកបានប្រឡងជាប់ហើយ បើអ្នកមិនទាន់បានប្រឡងជាប់ សញ្ញាប័ត្រមធ្យមសិក្សានៅឡើយទេ សូមផ្តល់ត្រឹមតែកំណត់ត្រាពិន្ទុ ឬព្រឹត្តិប័ត្រពិន្ទុមកសិន ហើយត្រូវផ្តល់សញ្ញាប័ត្រមធ្យមសិក្សាមកជាបន្ទាន់ ពេលបានប្រឡងជាប់ភ្លាម។ សូមបញ្ជាក់ថា មខសពិនិត្យតែពាក្យសុំរបស់សិស្សណា ដែលបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សារួចហើយ ឬសិស្សណាដែលកំពុងតែរៀននៅមហាវិទ្យាល័យទេ។

៣) ខាងក្រោមនេះ គឺជាឯកសារផ្លូវការ ត្រូវឲ្យសាលាចុះហត្ថលេខា និងចុះកាលបរិច្ឆេទជាផ្លូវការ អាចជាឯកសារតែ១ ឬក៏ច្រើនក៏បានដែរ :

ក- កំណត់ត្រាពិន្ទុ ឬព្រិត្តិប័ត្រពិន្ទុ School Transcript ចេញមកពីមហាវិទ្យាល័យ ឬក៏វិទ្យាល័យចុងក្រោយគេបង្អស់ ។

ខ- របាយការណ៍កំរិតថ្នាក់ចុងក្រោយ Final School Year GPA / Transcript បង្ហាញពីពិន្ទុមធ្យម Overall GPA

គ- ព្រឹត្តិប័ត្រពិន្ទុដំណាច់ឆ្នាំ Final School Year GPA / Transcript របស់វិទ្យាល័យ បង្ហាញពីកំរិតចុងក្រោយនៃការសិក្សារបស់អ្នក ។

ឃ- បើបានចូលមហាវិទ្យាល័យហើយ ត្រូវផ្តល់សញ្ញាប័ត្រCertificateបានមកពីវិទ្យាល័យ និង ព្រឹត្តិប័ត្រពិន្ទុ Transcript ចេញមកពីមហាវិទ្យាល័យ ។

ង- បើគ្មានកំណត់ត្រាពិន្ទុឬព្រិត្តិប័ត្រពិន្ទុ School Transcript មកពីមហាវិទ្យាល័យទេ អ្នកត្រូវតែផ្ញើ របាយការណ៍ប័ណ្ណសិក្សា១ Report Card ឬក៏ឯកសារទាំងឡាយណា ដែលបញ្ជាក់ចេញពីក្រសួងអបរំ ឬ ចេញពីសាលារៀន ឬពីគ្រូ ព្រមទាំងបញ្ជាក់នូវមុខវិជ្ជាទាំងអស់ ព្រមទាំងលទ្ធផលកំណត់ពិន្ទុដែលអ្នកបានរៀននៅឆមាសទី១ ឆ្នាំសិក្សាចុងក្រោយបង្អស់ ដោយមានចុះហត្ថលេខា និងកាលបរិច្ឆេទត្រឹមត្រូវ។ បើសិនអ្នកទើបតែប្រឡងជាប់បាក់ឌុបថ្មីៗ Baccalaureate 2 អ្នកត្រូវថតចម្លង និងផ្ញើសញ្ញាប័ត្របណ្តោះអាសន្ន ចេញដោយក្រសួងអប់រំ មកឲ្យយើងផង។

៤) សំបុត្រចុះឈ្មោះចូលរៀនឧត្តមសិក្សា Registration Letter អ្នកត្រូវផ្តល់ភស្តុតាងជាសំបុត្របញ្ជាក់ពីមហាវិទ្យាល័យ ដែលទទួលអ្នកឲ្យចូលរៀន។ អាចជាសំបុត្រជាផ្លូវការចេញពីសាលារៀន ឬ អ្នកអាចយកអត្តសញ្ញាណប័ណ្ណសាលាបច្ចុប្បន្ន ដែលសាលាធ្វើឲ្យប្រើក៏បាន ឬក៏ បង្កាន់ដៃបង់ថ្លៃសាលា Receipt of payment for School Tuition ឬក៏ លិខិតចេញពីសាលារៀនដែលបញ្ជាក់ថា អ្នកបានបង់ថ្លៃសិក្សាហើយ ឬក៏កំពុងតែចូលរៀននៅឆ្នាំសិក្សាថ្មីរួចហើយ ។

៥) បទនិពន្ធ Essayមាន២០០០ពាក្យ ជាភាសាខ្មែរ ឬភាសាអង់គ្លេស សេចក្តីនេះត្រូវសរសេរដោយខ្លួនអ្នកផ្ទាល់ សរសេរដៃ ឬបោះពុម្ព ឬដោយកុំព្យូទ័រ ហើយដែលអាចងាយអានបាន។ សូមដាក់ឈ្មោះពេញរបស់អ្នក ហើយចុះថ្ងៃខែ និងចុះហត្ថលេខាផង។ តទៅនេះ គឺជាគោលការណ៍ណែនាំទូទៅៈ

ក) ថ្លែងពីបំណង និងគោលដៅរបស់អ្នក ដែលប៉ងរៀនបន្តទៅឧត្តមសិក្សា ។

ខ) ថ្លែងពីមុខវិជ្ជាដែលអ្នកតាំងចិត្តរៀនយក។ សូមរៀបរាប់ពីការពិចារណាហេតុផលចំពោះវិស្ស័យសិក្សានេះ។

គ) ពិភាក្សាអំពីវិស្ស័យសិក្សានេះ ដែលអាចផ្តល់គុណប្រយោជន៍ដល់ខ្លួនអ្នក ដល់គ្រួសារ ដល់សង្គម និងប្រទេសជាតិ។

ឃ) ថ្លែងពីតម្លៃ ជំនឿ សង្គមសីលធម៌ និងការទទួលខុសត្រូវរបស់អ្នក ដែលអ្នកយកមកបម្រើសង្គមគ្រួសារ និងខេមរៈ ជនរួមជាតិទូទៅ។

ង) ជៀសវាងកុំធ្វើអធិប្បាយអំពីស្ថានភាពមានក្ររបស់អ្នក ឬរបស់គ្រួសារអ្នក ដែលជម្រុញឲ្យអ្នកស្វែងរកជំនួយអំពី**មខស**យើងនេះ។

ច) អត្ថបទនេះត្រូវសរសេរយ៉ាងសង្ខេប ហើយមានអត្ថន័យសំខាន់។ អត្ថបទនេះ នឹងឆ្លុះឲ្យឃើញនូវមនោគតិផ្ទាល់ខ្លួន គោលដៅ បំណងវិជ្ជាជីវៈ និងសីលធម៌របស់អ្នក ព្រមទាំងការទទួលខុសត្រូវរបស់អ្នក ដល់សង្គមគ្រួសារ និងប្រទេសជាតិ។ ការសរសេរវែងអន្លាយ លើសច្រើនពី២០០០ពាក្យ ហើយ

634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

ពុំមានសារៈសំខាន់នោះ នឹងនាំឲ្យខាតបង់សិទ្ធិទទួលអាហារូបករណ៍ទៅវិញទេ។

៦) លិខិតគាំទ្របីច្បាប់ 3 Letters of Support ជាភាសាខ្មែរ ឬភាសាអង់គ្លេស លិខិតនេះត្រូវសរសេរដោយគ្រូបង្រៀនរបស់អ្នក (យកល្អ គ្រូពីសាលាខុសៗគ្នា ហើយជាសាលាដែលអ្នកធ្លាប់បានរៀន) ឬដោយបុគ្គលណាដែលអាចដឹងនូវគុណសម្បត្តិរបស់អ្នក។ លិខិតនោះត្រូវមានលក្ខណៈដូចតទៅ៖

- ក) ឈ្មោះពេញរបស់អ្នកដែលសរសេរលិខិតគាំទ្រដល់អ្នក
- ខ) មុខងាររបស់អ្នកសរសេរលិខិតគាំទ្រ
- គ) ទំនាក់ទំនងអ្នកសរសេរលិខិតគាំទ្រ និងអ្នក ដូចជា គាត់ត្រូវជាគ្រូរបស់អ្នក ឬជាមិត្តភ័ក្ររបស់អ្នកជាដើម..
- ឃ) តើអ្នកសរសេរនោះស្គាល់អ្នកប៉ុនណាដែរ? ចំនួនប៉ុន្មានឆ្នាំ?
- ង) តើអ្នកសរសេរនោះដឹងពីស្ថានភាពមានក្ររបស់អ្នកដែរឬទេ?
- ច) តើអ្នកសរសេរនោះ ដឹងថាអ្នកមានគុណសម្បត្តិ អាចទទួលអាហារូបករណ៍អំពី **មខស** បានដែរឬទេ?
- ឆ) ចុះហត្ថលេខា និងថ្ងៃខែ នៃអ្នកសរសេរ

៧) ផ្តិតចម្លងអត្តសញ្ញាណប័ណ្ណ ឬអ្នកអាចយកអត្តសញ្ញាណប័ណ្ណបច្ចុប្បន្ន ដែលសាលាធ្វើឲ្យ មកប្រើក៏បានដែរ។

៨) **ឯកសារផ្សេងៗ** ៖ ផ្តល់ឯកសារណា ដែលអាចបញ្ជាក់ពីភាពក្រីក្រ ឬពីការរៀនបានពិន្ទុប្រពៃ ឬប័ណ្ណសរសើរចេញពីសាលាឬពីការងារ ដើម្បីជួយយោងពាក្យសុំអាហារូបករណ៍របស់អ្នក។ ឯកសារឯទៀត ដែលគួរផ្តល់មកជាមួយ មានការថតចម្លងសំបុត្រកម្មសិទ្ធិផ្ទះ សំបុត្របង្ហាញពីប្រាក់ចំណូល សំបុត្របង់ថ្លៃផ្ទះ សំបុត្របង់ថ្លៃពេទ្យ សំបុត្របញ្ជាក់ពីការបង់ខាត សំបុត្រដែលបង្ហាញពីបញ្ហាលំបាកវេទនានានាជាដើម។

## មខសយើងតម្រូវឲ្យមានឯកសារ ដូចខាងក្រោមទាំងអស់នេះ សំរាប់អ្នកសុំអាហារូបករណ៍ថ្មី

### Required Documents for New Applicant

សូមផ្ញើភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមនេះ គឺ ៖ (សូមគូសប្រអប់ដែលមានរបស់ផ្ញើភ្ជាប់មកជាមួយ)

[ ] រូបថត ទំហំ ៤០មម X ៦០មម ឬ៤ X ៦

[ ] អត្តសញ្ញាណប័ណ្ណជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណកូនសិស្ស ID Card or School ID Card

[ ] លិខិតយល់ព្រមអនុញ្ញាតឲ្យចូលរៀន( ឬលិខិតចុះឈ្មោះចូលរៀន) Registration Letter for new school year

[ ] បទនិពន្ធ Essay មាន២០០០ពាក្យ (ចុះហត្ថលេខា និង ចុះថ្ងៃ ខែ ឆ្នាំ)

[ ] កំណត់ត្រាពិន្ទុ**បញ្ចប់ឆ្នាំ**ពីសាលា (School Transcript / Overall GPA) និង សញ្ញាប័ត្រមធ្យមសិក្សា High School Diploma

[ ] លិខិតគាំទ្របីច្បាប់ 3 copies of Support Letter from 3 different persons

[ ] លិខិតផ្សេងទៀតដែលគួរផ្ញើមកឲ្យយើង គឺ៖ ____________________ _________________ _______________________

## មខសយើងតម្រូវឲ្យមាន ឯកសារដូចខាងក្រោមទាំងអស់នេះ សំរាប់អ្នកដែលធ្លាប់បានទទួលអាហារូបករណ៍ពីមុន

### Required Documents for Renewal Applicant

សូមផ្ញើភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមនេះ គឺ ៖ (សូមគូសប្រអប់ដែលមានរបស់ផ្ញើភ្ជាប់មកជាមួយ)

[ ] រូបថត ទំហំ ៤០មម X ៦០មម ឬ៤ X ៦

[ ] អត្តសញ្ញាណប័ណ្ណជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណកូនសិស្ស ID Card or School ID Card

634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

[ ] លិខិតយល់ព្រមអនុញ្ញាតឲ្យចូលរៀន( ឬលិខិតចុះឈ្មោះចូលរៀន ) Registration Letter for new school year

[ ] បទនិពន្ធ Essay មាន២០០០ពាក្យ (ចុះហត្ថលេខា និង ចុះថ្ងៃ ខែ ឆ្នាំ)

[ ] កំណត់ត្រាពិន្ទុ**បញ្ចប់ឆ្នាំ**ពីសាលា (School Transcript / Overall GPA) និង សញ្ញាប័ត្រមធ្យមសិក្សា High School Diploma

[ ] លិខិតផ្សេងទៀតដែលគួរផ្ញើមកឲ្យយើង គឺៈ ____________________ __________________ ________________________

ខាងក្រោមនេះ គឺជាឯកសារផ្លូវការ ត្រូវឲ្យសាលាចុះហត្ថលេខា និងកាលបរិច្ឆេទជាផ្លូវការ អាចជាឯកសារតែ១ ឬក៏ច្រើន :

១- របាយការណ៍កំរិតថ្នាក់ចុងក្រោយ Final School Year GPA / Transcript បង្ហាញពីពិន្ទុមធ្យម ( Overall GPA )

២- ព្រឹត្តិប័ត្រពិន្ទុដំណាច់ឆ្នាំរបស់វិទ្យាល័យ បង្ហាញពីកំរិតថ្នាក់ និងមុខវិជ្ជាទាំងអស់ ក្នុងពេលអ្នកសិក្សា ឬក៏ក្នុងរយះ ឆមាស ឬត្រីមាស ចុងក្រោយ នៃឆ្នាំចុងក្រោយ នៃការសិក្សារបស់អ្នក ។

៣- បើបានចូលមហាវិទ្យាល័យហើយ ត្រូវផ្តល់សញ្ញាប័ត្រ ទាំងវិទ្យាល័យ ទាំងមហាវិទ្យាល័យ ។

បើគ្មានព្រឹត្តិប័ត្រពិន្ទុ Transcript ពីមហាវិទ្យាល័យ អ្នកត្រូវតែផ្ញើ ប័ណ្ណរបាយការណ៍សិក្សា១ School Report Card ឬក៏ ឯកសារទាំងឡាយណា ដែលបញ្ជាក់ចេញពីក្រសួងអបរំ ឬ ចេញពីសាលារៀន ឬ ពីគ្រូ ព្រមទាំងបញ្ជាក់ នូវមុខវិជ្ជាទាំងអស់ ព្រមទាំងកំណត់ពិន្ទុ ដែលអ្នកបានរៀននៅ ឆមាសទី១ ក្នុងឆ្នាំសិក្សាចុងក្រោយបង្អស់ ដោយមានចុះហត្ថលេខា និងកាលបរិច្ឆេទត្រឹមត្រូវ ។ បើសិនអ្នកទើបតែ ប្រឡងជាប់ បាក់ឌុបថ្មីៗ (Baccalaureate 2) អ្នកត្រូវថតចម្លង និងផ្ញើសញ្ញាប័ត្របណ្តោះអាសន្ន ចេញដោយក្រសួងអប់រំ មកឲ្យ**មខស**យើងផង។

**សូមផ្ញើឯកសារទាំងអស់ មកឲ្យមខសយើងតាម Email នេះ : selecting@ceefoundation.org**

## ភាគទី១. សេចក្តីណែនាំក្នុងការបំពេញពាក្យសុំអាហារូបករណ៍

[១] សូមសរសេរ នាមត្រកូលនិងនាមខ្លួនរបស់អ្នក ជាភាសាខ្មែរ ។ នេះជាឈ្មោះដែលបានចែងក្នុងអត្តសញ្ញាណប័ណ្ណរបស់អ្នក ។

[២] សូមសរសេរ នាមត្រកូលនិងនាមខ្លួនរបស់អ្នក ជាអក្សរឡាតាំង ។ នេះជាឈ្មោះដែលបានចែងក្នុងអត្តសញ្ញាណប័ណ្ណរបស់អ្នក ។

[៣] សូមគូសប្រអប់ប្រាប់ពីភេទរបស់អ្នក ជា ស្រី ឬ ប្រុស។

[៤] សូមចុះ ថ្ងៃខែឆ្នាំ កំណើតរបស់អ្នក តាមលំដាប់ដូចបានចែងក្នុងពាក្យសុំ ពោលគឺ ឆ្នាំ ខែ ថ្ងៃ ។

[៥] សូមចុះទីកន្លែងដែលអ្នកកើត។ ត្រង់នេះ អាចមិនមែនជាទីកន្លែងដែលអ្នក និងឪពុកម្តាយអ្នកស្នាក់នៅសព្វថ្ងៃនោះទេ។ ដើម្បីឲ្យច្បាស់ សូមដកស្រង់ចេញពីសំបុត្រកំណើតរបស់អ្នក។

[៦] បើមានទូរស័ព្ទ សូមចុះលេខទូរស័ព្ទនៅទីនេះ។ ទូរស័ព្ទទី២ អាចជាទូរស័ព្ទកន្លែងធ្វើការ ប្រដាប់ Pager ឬក៏ជាទូរស័ព្ទរបស់មិត្ត ឬក្រុមគ្រួសាររបស់អ្នក ដែលអាចឲ្យយើងទាក់ទងជាមួយអ្នកបានងាយស្រួល។

[៧] បើអ្នកមាន អ៊ីមែល (Email) សូមចុះនៅទី នេះ។ ប្រសិនបើអ្នកមិនមានមធ្យោបាយទាក់ទង ដូចបានចែងខាងលើនេះទេ សូមប្រាប់យ៉ាងខ្លីៗពីរបៀបណាមួយដែលអាចឲ្យយើងទាក់ទងនឹងអ្នកបាន។

[៨] សូមចុះអាស័យដ្ឋាន ដែលអ្នករស់នៅសព្វថ្ងៃ ឬអាស័យដ្ឋានដែលអ្នកបំរុងនឹងទៅរស់នៅ នៅពេលរៀនឯមហាវិទ្យាល័យ។ សូមចុះឲ្យបានពេញលេញ (លេខផ្ទះ លេខផ្លូវ ក្រុម ខ័ណ្ឌ ភូមិ ឃុំ ស្រុក ខេត្រ)។ នេះជាទីកន្លែងសម្រាប់ផ្ញើសំបុត្រទាំងឡាយទៅអ្នក ពោលគឺជាទីដែលយើងអាចទាក់ទងជាមួយអ្នកបាន។

(៨.១) សូមគូសក្បៀសឲ្យចំប្រអប់ (Box) ដែលបានតម្រូវឲ្យឆ្លើយ

[៩] បើអាស័យដ្ឋានរបស់ឪពុកម្តាយអ្នក ខុសពីអាស័យដ្ឋានដូចបានឆ្លើយក្នុងសំនួរលេខ៥ខាងលើនោះ សូមចុះអាស័យដ្ឋានរបស់ឪពុកម្តាយអ្នកនៅទីនេះ ឲ្យបានពេញលេញ (លេខផ្ទះ លេខផ្លូវ ក្រុម ខ័ណ្ឌ ភូមិ ឃុំ ស្រុក ខែត្រ)។ អ្នកត្រូវឆ្លើយដោយគូសក្បៀសប្រអប់ផងដែរ ត្រង់ករណីដែលអ្នកបាន ឬមិនបាន រស់នៅជាមួយឪពុកម្តាយ កាលកំពុងនៅរៀនឯវិទ្យាល័យ ហើយគូសបញ្ជាក់ពីទីដែលអ្នកបានរស់នៅនោះ ជាទីជនបទ ឬទីក្រុង ។ល។

[៩.១] សូមគូសបញ្ជាក់អំពីលក្ខណៈគេហដ្ឋានរបស់ឪពុកម្តាយ តើសង់ពីអ្វី? បើជាផ្ទះជួល សូមចុះតម្លៃឈ្នួល ជាលុយរៀល ឬជាលុយដុល្លា។

[៩.២] សូមគូសប្រអប់ឲ្យបានត្រឹមត្រូវ បញ្ជាក់អំពីអ្នកដែលរស់នៅក្នុងគេដ្ឋានរបស់ឪពុកម្តាយ។

[១០] សូមចុះឈ្មោះពេញរបស់ឪពុកអ្នក។ បើគាត់ស្លាប់ គូសត្រង់ប្រអប់ ស្លាប់។ បើគាត់នៅរស់ ប្រាប់ពីអាយុរបស់គាត់ ដោយគូសប្រអប់អាយុក្រោម ឬ លើ ៦០ឆ្នាំ។ សូមគូសក្បៀសប្រាប់ពីសុខភាព ភាពរៀបការ និងមុខរបររកស៊ីរបស់គាត់។ បើគាត់ជាអ្នកជំនួញ ពាណិជ្ជករ សូមប្រាប់ពីប្រភេទមុខជំនួញនោះ ដូចជាលក់ចាប់ហួយនៅទីផ្សារជាដើម។ បើគាត់ជាអ្នករដ្ឋការ សូមប្រាប់ពីប្រភេទមុខការនោះ។ បើគាត់ចូលនិវត្តន៍ហើយ ឬគ្មានការងារធ្វើទេ សូមគូសក្បៀសត្រង់ប្រអប់ដែលត្រឹមត្រូវ។

[១១] សូមចុះឈ្មោះពេញរបស់ម្តាយអ្នក។ បើគាត់ស្លាប់ គូសត្រង់ប្រអប់ស្លាប់។ បើគាត់នៅរស់ ប្រាប់ពីអាយុរបស់គាត់ ដោយគូសប្រអប់អាយុក្រោម ឬ លើ៦០ឆ្នាំ។ សូមគូសក្បៀសប្រាប់ពីសុខភាព ភាពរៀបការ និងមុខរបររកស៊ីរបស់គាត់។ បើគាត់នៅផ្ទះ សូមសរសេរ មេផ្ទះ។ បើជាអ្នកជំនួញ សូមប្រាប់ពីប្រភេទមុខជំនួញនោះ ដូចជាលក់ចាប់ហួយនៅទីផ្សារជាដើម។ បើគាត់ជាអ្នករដ្ឋការ សូមប្រាប់ពីប្រភេទមុខការនោះ។ បើគាត់ចូលនិវត្តន៍ហើយ ឬគ្មានការងារធ្វើទេ សូមគូសក្បៀសត្រង់ប្រអប់ដែលត្រឹមត្រូវ។

[១២] សូមចុះប្រាក់ចំណូល ជារៀល ឬដុល្លា របស់ឪពុកម្តាយអ្នក ដោយឡែកពីគ្នា។

[១៣] ចំនួនបងប្អូនបង្កើតទាំងអស់ ដែលមានអាយុ ១៨ ឆ្នាំ និងចុះក្រោម ហើយ ដែលនៅក្នុងទំនុកបម្រុង របស់ឪពុកម្តាយអ្នកសព្វថ្ងៃ។

[១៣.១] សូមចុះចំនួនបងប្អូនដែលកំពុងនៅរៀនឧត្តមសិក្សាសព្វថ្ងៃ .

[១៤] សូមគូសក្បៀសឲ្យចំប្រអប់សំនួរដែលទាក់ទងនឹងជីវិតរស់នៅសព្វថ្ងៃរបស់អ្នក។ សំនួរនេះទាក់ទងនឹងសំនួរលេខ៥ខាងលើ ដែលសួរពីសភាពរស់នៅរបស់អ្នក ពេលកំពុងនៅរៀនឯមហាវិទ្យាល័យ។ សូមប្រាប់ថា អ្នករស់នៅជាមួយឪពុកម្តាយ ឬស្នាក់នៅឯវត្ត ឬអាសយ័ដ្ឋានដោយមិនបានបង់ប្រាក់ឈ្នួលទេ ឬក៏អ្នកជួលផ្ទះនៅ។ បើជួលផ្ទះនៅ តើប្រាក់ឈ្នួលមួយខែប៉ុន្មាន។ បើអ្នកកំពុងនៅរៀនឯវិទ្យាល័យនៅឡើយទេនោះ សូមគូសក្បៀសត្រង់ប្រអប់ "នឹងជម្រាបពេលក្រោយ"។

[១៥] សូមគូសប្រាប់អំពីតម្លៃសាលា តើចំនួនប៉ុន្មាន? បើមានបុគ្គល ឬអង្គការណា ក្រៅពីឪពុកម្តាយអ្នក បានជួយបង់ថ្លៃឈ្នួលសាលាឲ្យអ្នក សូមពន្យល់នៅទីនេះ។ អ្នកត្រូវពន្យល់បញ្ជាក់ថា តើអ្នកអាចចេញថ្លៃឈ្នួលសាលា ព្រមទាំងការចំណាយលើខ្លួនអ្នក ដោយរបៀបណាដែរ? អ្នកត្រូវឆ្លើយសំណួរនេះឲ្យបានច្បាស់លាស់។ បើត្រូវការចន្លោះសំរាប់ឆ្លើយច្រើនជាងហ្នឹង បន្ទាប់ពីបានចុះហត្ថលេខា នៅបន្ទាត់លេខ២៦រួចហើយ សូមសរសេរបន្ថែមនៅពីខាងក្រោមទៀតក៏បានដែរ។

[១៦] សូមប្រាប់នៅត្រង់នេះ អំពីប្រាក់ជំនួយផ្សេងៗ ដែលអ្នកអាចបានទទួលរួចមកហើយ ឬបម្រុងនឹងទទួល ពីអង្គការដទៃក្រៅពី មូលនិធិខ្មែរ? ម្រាប់ការសិក្សា (មខស)។ ជំនួយទាំងនេះ រាប់បញ្ចូលជាបីផ្នែក៖ ឈ្នួលសាលា ប្រាក់ចាយវាយ និងអាហារូបករណ៍។ សូមគូសឲ្យចំប្រអប់ត្រឹមត្រូវ ហើយចុះចំនួនទឹកប្រាក់សរុប ពោលគឺ បើអ្នក(នឹង)បានទទួលជំនួយទាំងអស់បី ត្រូវបូកប្រាក់ជំនួយទាំងបី ហើយចុះចំនួនដែលបូកចូលគ្នានោះ។

634 Oakwood Court, Westbury, NY 11590

EMail: Selecting@ceefoundation.org www.ceefoundation.org




**[១៧]** សូមគូសក្បៀសឲ្យចំប្រអប់សំនួរដែលទាក់ទងនិងអ្នក តើអ្នកមានសាច់ញាតិជិតស់នៅបរទេសឬទេ?

[១៧.២] បើមាន តើគាត់រស់នៅប្រទេសណាដែរ សូមប្រាប់ឈ្មោះ? ___________

**[១៨]** សូមប្រាប់ថា អ្នកកំពុងមានការងារធ្វើ ជាពេញម៉ោង ឬមិនពេញម៉ោង។ មខស យល់ឃើញថា ការមានការងារជាគុណភាពប្រពៃសមរម្យល្អណាស់ ទោះជាអ្នករកបានប្រាក់ចំណូលប៉ុន្មានក៏ដោយ។ យើងលើកទឹកចិត្តការធ្វើការងារ ដើម្បីបានប្រកបភាពជំនាញក្នុងវិជ្ជាជីវៈ។ គំនិតធ្វើការងារ ការសាកល្បងរកវិធីជួយផ្គត់ផ្គង់ខ្លួន ការមិនពឹងផ្អែកតែទៅលើជំនួយអ្នកដទៃ ទាំងអស់នេះសុទ្ធតែជាគុណភាពប្រពៃ ដែលគណកម្មាធិការជ្រើសរើសយកមកពិនិត្យដ៏ល្អិតល្អន់ ក្នុងការផ្តល់រង្វាន់អាហារូបករណ៍។

[១៨.១] មិនកង្វល់ថាអ្នកធ្វើការឬអត់ទេ សូមបញ្ជាក់ថា តើអ្នកត្រូវការចំណាយសរុបប៉ុន្មានដែរក្នុង១ខែៗ? ដោយមិនរាប់បញ្ចូលថ្លៃឈ្នួលសាលា ។

**[១៩]** សូមប្រាប់ពីមធ្យាបាយដែលអ្នកធ្វើដំណើរទៅសាលារៀនរាល់ថ្ងៃ។ បើអ្នកដើរ តើដំណើរមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ រាប់ទាំងទៅ ទាំងមក។ បើប្រើយានជំនះ សូមចុះចំណាយក្នុងយានជំនិះទាំងអស់ គឺរាប់ទាំងថ្លៃជិះយានសាធារណៈ ការចាយវាយលើយានជំនិះផ្សេងទៀត ដូចជា ជិះមូតូឌុប ជាដើម។

**[២០]** ឈ្មោះវិទ្យាល័យចុងក្រោយដែលអ្នកបានរៀន ________________________________________________

អាស័យដ្ឋានវិទ្យាល័យនោះ ____________________________________________________________

[២០.១] ថ្ងៃ ខែ ឆ្នាំ ដែលអ្នកបាន ឬបម្រុងនឹងរៀនចប់ ________________________

[២០.២] សូមផ្តល់សញ្ញាប័ត្របាក់ឌុប( Baccalaureate Certificate or High School Diploma) ពីវិទ្យាល័យ ហើយនិងព្រឹត្តិប័ត្រពិន្ទុ (Transcript)ពីវិទ្យាល័យ ឬពីមហាវិទ្យាល័យ ចុងក្រោយបង្អស់ ។

១ - របាយការណ៍កំរិតថ្នាក់ចុងក្រោយ បង្ហាញពិន្ទុមធ្យម ( Overall GPA )

២- ព្រឹត្តិប័ត្រពិន្ទុដំណាច់ឆ្នាំរបស់វិទ្យាល័យ ឬមហាវិទ្យាល័យ បង្ហាញពីកំរិតថ្នាក់ និងមុខវិជ្ជាទាំងអស់ក្នុងពេលអ្នកសិក្សា ឬក៏ក្នុងរយះឆមាស ឬ ត្រីមាស ចុងក្រោយ នៃឆ្នាំចុងក្រោយ នៃការសិក្សារបស់អ្នក ។

៣- បើបានចូលមហាវិទ្យាល័យហើយ ត្រូវផ្តល់សញ្ញាប័ត្រ(Certificate)បានមកពីវិទ្យាល័យ និង ព្រឹត្តិប័ត្រពិន្ទុ (Transcript)ពីមហាវិទ្យាល័យ

**[២១]** សូមចុះឈ្មោះ និងអាស័យដ្ឋានមហាវិទ្យាល័យ។ សូមបញ្ជាក់ទីកន្លែងសាខា បើជាសាខា។

[ ២១.១] សូមគូសក្បៀសឲ្យចំប្រអប់សំនួរដែលទាក់ទង នឹង ពីថ្នាក់(ឆ្នាំ) ជាពេញម៉ោង ឬមិនពេញម៉ោង ដែលអ្នកកំពុងរៀន។ បើនៅមធ្យមសិក្សានៅឡើយ សូមពន្យល់បន្ថែមផង។ សូមចុះ ថ្ងៃខែឆ្នាំ ដែលអ្នកបានចូលទៅរៀនហើយ ឬបម្រុងនឹងចូលទៅរៀន។ សូមចុះថ្ងៃខែឆ្នាំ ដែលអ្នកនឹងបានរៀនចប់ (ប្រឡងជាប់)។

[២១.២] សូមប្រាប់ថ្ងៃខែឆ្នាំ ដែលអ្នកបម្រុងនឹងរៀន នៅមហាវិទ្យាល័យ។

[២១.៣] សូមប្រាប់ថ្ងៃខែឆ្នាំ ដែលអ្នកនឹងបានរៀនចប់

[២១.៤] សូមប្រាប់សញ្ញប័ត្រដែលអ្នកកំពុង ឬបម្រុងនឹងរៀនយក ព្រមទាំងមុខវិជ្ជាសិក្សា។

[ ] បរិញ្ញាប័ត្ររង [ ] បរិញ្ញាប័ត្រ [ ] អនុបណ្ឌិត [ ] ផ្សេង __________________________

មុខវិជ្ជាសិក្សា ដែលអ្នកកំពុង ឬបម្រុងនឹងរៀនយក (Major) ___________________________________

[២១.៥] សូមផ្តល់មកនូវ ព្រឹត្តិប័ត្រពិន្ទុ ឬកំណត់ត្រាពិន្ទុពីសាកលវិទ្យាល័យ (University Transcript) ចុងក្រោយ

[២១.៥.១] សាលាប្រើ GPA Grading System អ្នកត្រូវបញ្ចូល GPA ( ៣ ៤ ៥ ) ____________

[២១.៥.២] សាលាប្រើ Letter Grade System អ្នកត្រូវបញ្ចូល Letter Grade *( B+ /A ):* ____________________

634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org



[២១.៥.៣] សាលាប្រើ Scoring Systemផ្សេងទៀត អ្នកត្រូវបញ្ចូល Score: ______Score: ខ្ពស់ជាងគេ________

[២១.៥.៤] បើអត់ទាន់មាន(សូមពន្យល់) ________________________________________________________________

ព្រឹត្តិប័ត្រពិន្ទុ (Transcript)ពីមហាវិទ្យាល័យចុងក្រោយ

១- របាយការណ៍កំរិតថ្នាក់ចុងក្រោយ បង្ហាញពិន្ទុមធ្យម ( Overall GPA )

២-ព្រឹត្តិប័ត្រពិន្ទុដំណាច់ឆ្នាំរបស់វិទ្យាល័យ ឬមហាវិទ្យាល័យ បង្ហាញពីកំរិតថ្នាក់ និងមុខវិជ្ជាទាំងអស់ក្នុងពេលអ្នកសិក្សា ឬក៏ក្នុងរយះឆមាស ឬត្រីមាសចុងក្រោយនៃឆ្នាំចុងក្រោយនៃការសិក្សារបស់អ្នក ។

៣-បើបានចូលមហាវិទ្យាល័យហើយ ត្រូវផ្តល់សញ្ញាប័ត្រ(Certificate)បានមកពីវិទ្យាល័យ និងព្រឹត្តិប័ត្រពិន្ទុ (Transcript)ពីមហាវិទ្យាល័យ បើគ្មាន ព្រឹត្តិប័ត្រពិន្ទុ (Transcript) ពីមហាវិទ្យាល័យ អ្នកត្រូវតែផ្ញើ ប័ណ្ណរបាយការណ៍សិក្សា១( School Report Card) ឬក៏ឯកសាទាំងឡាយណាដែលបញ្ជាក់ចេញពីក្រសួងអបរំ ឬ ចេញពីសាលារៀន ឬ ពីគ្រូ ព្រមទាំងបញ្ជាក់ នូវមុខវិជ្ជាទាំងអស់ ព្រមទាំង កំណត់ពិន្ទុ ដែលអ្នកបានរៀននៅ ឆមាសទី១ ឆ្នាំសិក្សាចុងក្រោយបង្អស់ ដោយមានចុះហត្ថលេខា និង កាលបរិច្ឆេទ ត្រឹមត្រូវ ។ បើសិន អ្នកទើបតែ ប្រឡងជាប់បាក់ឌុបថ្មីៗ (Baccalaureate 2) អ្នកត្រូវថតចម្លង និងផ្ញើសញ្ញាប័ត្របណ្តោះអាសន្ន ចេញដោយក្រសួងអប់រំមកឲ្យយើង។

**[២២]** ពេលចូលរៀនមហាវិទ្យាល័យ (ដូចបានឆ្លើយនៅសំនួរលេខ២១) បើអ្នកទៅរៀនសាលាណាផ្សេងទៀតផងដែរ សូមបញ្ជាក់ឈ្មោះសាលានោះ(អស់នោះ) ព្រមទាំងវិស័យសិក្សា ឬប្រធានមុខវិជ្ជាដែលអ្នករៀន។

**[២៣]** សូមប្រាប់ពីការបានទទួលរង្វាន់ពីសាលា ឬពីក្រសួងសិក្សាធិការ យុវជន និងកីឡា ឬពីអង្គការដទៃផ្សេងទៀត ។ រង្វាន់នោះ គួរតែទាក់ទងទៅនឹងការសិក្សា ដូចជា ជោគជ័យក្នុងការប្រឡង ការបានសំរេចមុខវិជ្ជាជាន់ខ្ពស់ ឬក៏សញ្ញាប័ត្រហ្វឹកហ្វឺនមុខវិជ្ជាណាមួយ។ សូមផ្តល់លិខិតភស្តុតាងនៃរង្វាន់នោះមកផង។

**[២៤]** សូមប្រាប់ពីសកម្មភាពដែលអ្នកបានធ្វើក្រៅពីកិច្ចការសាលា។ នេះមានសកម្មភាពកីឡា ការរៀបចំពិធីការ ការស្ម័គ្រចិត្តបម្រើសង្គម នៅមន្ទីរពេទ្យ កន្លែងសង្គ្រោះ ។ល។ **មខស** ឲ្យតម្លៃ និងលើកទឹកចិត្តឲ្យមានសកម្មភាពក្រៅសាលា និងការស្ម័គ្រចិត្តបម្រើសង្គមយ៉ាងខ្លាំង។ យើងយកចិត្តទុកដាក់យ៉ាងច្រើនទៅលើសកម្មភាពក្រៅសាលា ក្នុងការពិនិត្យជ្រើសរើសនិស្សិតឲ្យទទួលអាហារូបករណ៍។

## [២៥] <u>សេចក្តីប្រកាស</u>

សូមអានដោយពិនិត្យពិច័យបំផុត ហើយត្រូវយល់ស្របទាំងស្រុងនូវសេចក្តីត្រូវការទាំងឡាយ ដែល **មខស** តម្រូវយក ដើម្បីឲ្យអ្នកមានសិទ្ធិអាចទទួលអាហារូបករណ៍បាន។ នេះរាប់ទាំងបេសកកម្ម បំណង តម្លៃ និងទស្សនះរបស់ **មខស**។ សូមអានវិបសាយWebsiteនេះជាបន្ថែម ដើម្បីពត៌មានពិស្តារ www.ceefoundation.org។ អ្នកត្រូវតែគូសប្រអប់ទាំងបី ដើម្បីប្រកាសថាយល់ព្រមតាមសេចក្តីទាំងឡាយដែលអ្នកបានចុះជារៀងមកនេះ។ ប្រសិនបើអ្នកមិនគូសយល់ព្រមក្នុងគ្រប់ចំណុចទាំង៣នេះទេ នោះ**មខស** នឹងមិនយកពាក្យសុំរបស់អ្នកមកពិនិត្យឡើយ។

## [២៦] ហត្ថលេខា និង ថ្ងៃ ខែ ឆ្នាំ

អ្នកត្រូវតែចុះហត្ថលេខា ហើយដាក់ ថ្ងៃ ខែ ឆ្នាំ លើពាក្យសុំ ព្រោះបើមិនធ្វើទេ នោះ **មខស** នឹងមិនយកពាក្យសុំរបស់អ្នកមកពិនិត្យឡើយ។

មូលនិធិខ្មែរសម្រាប់ការសិក្សា
CAMBODIAN EDUCATION EXCELLENCE FOUNDATION
634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

# ពាក្យសុំអាហារូបករណ៍

ត្រូវគៀសប្រអប់ (Box) នេះ [ ] អាហារូបករណ៍ថ្មី [ ] បានទទួលអាហារូបករណ៍ពីមុន ឆ្នាំសិក្សា ២០១___ ២០១__

១. គោត្តនាម នាម ជាខ្មែរ : ______________________________

២. Full Name in English : ______________________________

(Family Name, Given Name in capital letter)

៣. ភេទរបស់អ្នក [ ] ប្រុស [ ] ស្រី

៤. ថ្ងៃ ខែ ឆ្នាំ កំណើត ថ្ងៃទី__________ ខែ__________ ឆ្នាំ__________

៥. ទីកន្លែង កំណើត ______________________________

(ភូមិ ឃុំ ទីក្រុង ស្រុក ឬ ខេត្រ)

៦. ទូរស័ព្ទទី១(______) __________ ទូរស័ព្ទទី២ (______) __________

៧. E-Mail __________ ឬតើ ឲ្យយើងទាក់ទងតាមមធ្យោបាយណា? __________

៨. ទីលំនៅបច្ចុប្បន្នរបស់សិស្ស (ទីលំនៅសព្វថ្ងៃ ឬពេលចូលរៀនឧត្តមសិក្សា) __________

[ ]តំបន់ភ្នំពេញ [ ]ទីប្រជុំខេត្រ [ ]ទីប្រជុំស្រុក [ ]ជនបទ

៨.១: ពេលរៀនមធ្យមសិក្សា តើអ្នករស់នៅជាមួយឪពុកម្ដាយឬ? [ ] នៅជាមួយ [ ] មិននៅជាមួយទេ

៩. ទីលំនៅរបស់ឪពុកម្ដាយ (បើដូចអាស័យដ្ឋានខាងលើ — សំនួរទី៥ ឬសំនួរទី ៨ — សូមសរសេរ "ដូចសំនួរទី៥ ឬទី៨ខាងលើ")

______________________________

[ ]តំបន់ភ្នំពេញ [ ]ទីប្រជុំខេត្រ [ ]ទីប្រជុំស្រុក [ ]ជនប

៩.១ គេហដ្ឋានឪពុកម្ដាយជាផ្ទះផ្ទាល់ខ្លួនរបស់ឪពុកម្ដាយឬ? [ ] ផ្ទះផ្ទាល់ខ្លួន [ ] មិនមែនផ្ទះផ្ទាល់ខ្លួនទេ

បើផ្ទះខ្លួនឯង តើសង់អំពីអ្វី? [ ] ថ្ម [ ] ឈើ [ ] ស្បូវឬស្លឹក

បើផ្ទះជួល តើថ្លៃជួលមួយខែប៉ុន្មាន? __________ [ ] រៀល [ ] ដុល្លា

៩.២ នៅគេហដ្ឋានឪពុកម្ដាយ តើមានក្រុមគ្រួសារឯទៀតនៅជាមួយឬទេ? [ ] មាន [ ] មិនមានទេ

១០. ឪពុក ឈ្មោះ ______________________________

១០.១ [ ] អាយុលើ ៦០ឆ្នាំ [ ] អាយុក្រោម ៦០ឆ្នាំ [ ] ស្លាប់

១០.២ សុខភាពឪពុក [ ] សុខភាពល្អធម្មតា [ ] មានរោគាព្យាធិប្រចាំ ឬពិកា

១០.៣ ស្ថានភាពអាពាហ៍ពិពាហ៍របស់ឪពុក [ ] មានភរិយាពេញច្បាប់ [ ] ពោះម៉ាយ

១០.៤ មុខរបរឪពុក [ ] អ្នករកស៊ី (មុខរបរអ្វី?) __________

[ ] អ្នករដ្ឋការ (កិច្ចការអ្វី?) __________

[ ] ចូលនិវត្តន៍ [ ] ឥតការធ្វើ [ ] កសិករ ឬកម្មករ

*634 Oakwood Court, Westbury, NY 11590* *EMail: Selecting@ceefoundation.org* *www.ceefoundation.org*


Rev9 – Oct. 12

**១១.** ម្តាយ ឈ្មោះ ______________________________

១១.១ [ ] អាយុលើ ៦០ឆ្នាំ [ ] អាយុក្រោម ៦០ឆ្នាំ [ ] ស្លាប់

១១.២ សុខភាពម្តាយ [ ] សុខភាពល្អធម្មតា [ ] មានរោគាព្យាធិប្រចាំ ឬពិការ

១១.៣ ស្ថានភាពអាពាហ៍ពិពាហ៍របស់ម្តាយ [ ] មានស្វាមីពេញច្បាប់ [ ] មេម៉ាយ

១១.៤ មុខរបរម្តាយ [ ] អ្នករកស៊ី (មុខរបរអ្វី?) ______________________________

[ ] អ្នករដ្ឋការ (កិច្ចការអ្វី?) ______________________________

[ ] ចូលនិវត្តន៍ [ ] ឥតការធ្វើ [ ] កសិករ ឬកម្មករ

**១២.** សរុបប្រាក់ចំណូល ក្នុងមួយខែ របស់ឪពុកម្តាយ (រាប់ប្រាក់ចំណូលទាំងអស់ ជារៀលឬជាដុល្លាអាមេរិកាំង)

ឪពុក ________ [ ] រៀល [ ]ដុល្លា ម្តាយ __________ [ ] រៀល [ ] ដុល្លា

**១៣.** ចំនួនបងប្អូនបង្កើតទាំងអស់ ដែលមានអាយុ ១៨ ឆ្នាំ និងចុះក្រោម ហើយដែលនៅក្នុងបន្ទុករបស់ឪពុកម្តាយអ្នកសព្វថ្ងៃ(មិនរាប់ខ្លួនអ្នកទេ)_______

១៣.១ ចំនួនបងប្អូនបង្កើតដែលនៅរៀនឧត្តមសិក្សាសព្វថ្ងៃ ________ នាក់

**១៤.** សូមអធិប្បាយអំពីការរស់នៅរបស់អ្នក នៅពេលអ្នកចូលរៀនឧត្តមសិក្សា (តាមអាស័យដ្ឋានចុះក្នុងសំនួរទី៨)

[ ] នឹងជម្រាបជូនពេលក្រោយ ព្រោះខ្ញុំនៅរៀនមធ្យមសិក្សានៅឡើយ ហើយកំពុងដាក់ពាក្យសុំចូលសាកលវិទ្យាល័យ

[ ] នៅជាមួយឪពុកម្តាយ ឬបងប្អូនដោយមិនបង់ថ្លៃផ្ទះ

[ ] នៅជួលផ្ទះ ឬនៅរួមជាមួយអ្នកដទៃដោយបង់ថ្លៃជួលមួយខែចំនួន ____________ [ ] រៀល [ ] ដុល្លា

[ ] នៅវត្ត ឬសយ័នដ្ឋាន(Dormitory) ដោយមិនបង់ថ្លៃផ្ទះ

**១៥.** តើអ្នកបង់ ឬនឹងបង់ ថ្លៃសាលាឬទេ? [ ] បាទ/ចាស ខ្ញុំបង់ ក្នុងមួយឆ្នាំ ចំនួន ________________ [ ] រៀល [ ] ដុល្លា

[ ] ទេ ខ្ញុំមិនបង់ទេ ព្រោះ (សូមពន្យល់) ______________________________

អ្នកត្រូវពន្យល់បញ្ជាក់ថា តើអ្នកអាចចេញថ្លៃឈ្នួលសាលា ព្រមទាំងការចំណាយលើខ្លួនអ្នក ដោយរបៀបណាដែរ?

អ្នកត្រូវឆ្លើយសំណួរនេះឲ្យបានច្បាស់លាស់ បើត្រូវការចន្លោះសំរាប់ឆ្លើយច្រើនជាងហ្នឹង បន្ទាប់ពីបានចុះហត្ថលេខានៅសំនួរលេខ២៦រួចហើយសូមសរសេរ

______________________________

______________________________

**១៦.** តើអ្នកបាន ឬបម្រុងនឹង ទទួលប្រាក់ជំនួយដទៃទៀតក្រៅពីអាហារូបករណ៍របស់ មូលនិធិខ្មែរសម្រាប់ការសិក្សា ឬទេ?

[ ] បាទ/ចាស ខ្ញុំទទួលប្រាក់សម្រាប់បង់ថ្លៃសាលា ពីសាកលវិទ្យាល័យ ចំនួន____________ [ ] រៀល [ ] ដុល្លា

[ ] បាទ/ចាស ខ្ញុំទទួល អាហារូបករណ៍ ពី ______________________________

ចំនួន ___________ [ ] រៀល [ ] ដុល្លា ក្នុងមួយ [ ] ខែ [ ] ឆមាស [ ] ឆ្នាំ

[ ] បាទ/ចាស ខ្ញុំទទួល ប្រាក់ជំនួយ ពី ______________________________

ចំនួន ___________ [ ] រៀល [ ] ដុល្លា ក្នុងមួយ [ ] ខែ [ ] ឆមាស [ ] ឆ្នាំ

[ ] បាទ/ចាស ខ្ញុំទទួលប្រាក់សម្រាប់បង់ថ្លៃសាលា និង អាហារូបករណ៍ ពី ____________________

ចំនួន ___________ [ ] រៀល [ ] ដុល្លា ក្នុងមួយ [ ] ខែ [ ] ឆមាស [ ] ឆ្នាំ

[ ] ទេ ខ្ញុំមិនបានទទួលជំនួយអ្វីទាំងអស់

**១៧.** តើអ្នកមានសាច់ញាតិជិត រស់នៅបរទេសដែរឬទេ? [ ] ឥតមានទេ [ ] មាន

១៧.១ បើមាន តើជានរណា? [ ]ឪពុកម្តាយ [ ]បងប្អូនបង្កើត [ ]មីងមា [ ] ជូនតា

១៧.២ បើមាន តើនៅប្រទេសណា? ______________________________

634 Oakwood Court, Westbury, NY 11590
EMail: Selecting@ceefoundation.org www.ceefoundation.org

Rev9 – Oct. 12

១៨. សព្វថ្ងៃ តើអ្នកធ្វើការឬទេ? [ ] ខ្ញុំឥតធ្វើការទេ [ ] ខ្ញុំធ្វើការ ប្រាក់ចំណូលមួយខែ________ [ ] រៀល [ ] ដុល្លា

១៨.១ ចំណាយសារុបរបស់អ្នកក្នុង១ខែ ដោយមិនរាប់បញ្ចូលថ្លៃសាលារៀន ________ [ ] រៀល [ ] ដុល្លា

១៩. កាលបានចូលរៀនសាកលវិទ្យាល័យ តើអ្នកធ្វើដំណើរទៅសាលាដោយវិធីណា?

[ ] ដើរ ចម្ងាយ(ទៅ+មក)________គ.ម. [ ] ជិះកង់ [ ] ជិះម៉ូតូ

[ ] ជិះយានសាធារណៈ [ ] បើកឡានខ្លួនឯង [ ] ជិះ និងរួមចំណាយ ជាមួយមិត្តភ័ក្តិ

២០. ឈ្មោះវិទ្យាល័យចុងក្រោយដែលអ្នករៀន ________________________________________________

អាស័យដ្ឋានវិទ្យាល័យ ________________________________________________________________________________

[ ] តំបន់ភ្នំពេញ [ ] ទីប្រជុំខេត្ត [ ] ទីប្រជុំស្រុក [ ] ជនបទ

២០.១ ថ្ងៃ ខែ ឆ្នាំ ដែលអ្នកបាន ឬបម្រុងនឹង រៀនចប់ _________________________

២០.២ សូមផ្តល់សញ្ញាប័ត្របាក់ឌុប( High School Diploma) ពីវិទ្យាល័យ ហើយនិង ព្រឹត្តិប័ត្រពិន្ទុ (Transcript ) ពីវិទ្យាល័យ

GPA (e.g., 3.5/4): _______ Grade (e.g. A+, A, B): _______ ឬ ពន្ទុផ្សេងទៀត __________

[ ] អត់ទាន់មាន(សូមពន្យល់) _______________________________________________________________

២១. ឈ្មោះសាកលវិទ្យាល័យ/វិទ្យាស្ថាន ដែលអ្នកបាន ឬបម្រុងនឹង ចូលរៀន _____________________________________

ទីកន្លែងសាខា (Campus)________________________________________________________

២១.១ អ្នកនឹងជានិស្សិត [ ] ពេញម៉ោង [ ] មិនពេញម៉ោង

តើបានយកថ្នាក់រៀនថ្នាក់(Courses)ប៉ុន្មាន? : ___________________ [ ] ត្រីមាស [ ] ឆមាស [ ] ឆ្នាំ

ជានិស្សិត [ ] ឆ្នាំទី១ [ ] ឆ្នាំទី២ [ ] ឆ្នាំទី៣ [ ] ឆ្នាំទី៤ [ ] ឆ្នាំទី៥

[ ] ផ្សេងទៀត ______________________________________________

២១.២ ថ្ងៃខែឆ្នាំ ដែលអ្នកនឹងបាន**ចូលរៀន** នៅសាកលវិទ្យាល័យ/វិទ្យាស្ថាន (ខែ / ឆ្នាំ): ____/ ____

២១.៣ ថ្ងៃខែឆ្នាំ ដែលអ្នកនឹងបាន**រៀនចប់** នៅសាកលវិទ្យាល័យ/វិទ្យាស្ថាន (ខែ ឆ្នាំ ) ______________________

២១.៤ សញ្ញាប័ត្រ ដែលអ្នកកំពុង ឬបម្រុងនឹង រៀនយក?

[ ] បរិញ្ញាប័ត្ររង [ ] បរិញ្ញាប័ត្រ [ ] អនុបណ្ឌិត [ ] ផ្សេង ________________________

មុខវិជ្ជាសិក្សា ដែលអ្នកកំពុង ឬបម្រុងនឹង រៀនយក (Major) ________________________________

២១.៥ សូមផ្តល់មកនូវកំណត់ត្រាពិន្ទុ ពីសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ (University Transcript) ចុងក្រោយ

២១.៥.១ [ ] បើសាលាប្រើ GPA Grading System អ្នកត្រូវបញ្ចូល GPA (៣ ៤ ៥) ____________

២១.៥.២ [ ] បើសាលាប្រើ Letter Grade System អ្នកត្រូវបញ្ចូល Letter Grade ( B+/A): _________________

២១.៥.៣ [ ] បើសាលាប្រើ Scoring System ផ្សេងទៀត អ្នកត្រូវបញ្ចូល Score: _____ Score: ខ្ពស់ជាងគេ________

២១.៥.៤ [ ] អត់ទាន់មាន(សូមពន្យល់) ____________________________________________________________

២២. តើអ្នករៀននៅវិទ្យាស្ថានដទៃដែរឬ នៅពេលដែលអ្នកកំពុងរៀននៅសាលាក្នុងសំនួរ២១? [ ] អត់ទេ

[ ] ខ្ញុំរៀនដែរ នៅសាលា ឈ្មោះ ______________________________ មុខវិជ្ជា ____________________

និងសាលាមួយទៀត ឈ្មោះ __________________________________ មុខវិជ្ជា ____________________

២៣. តើអ្នកបានទទួលរង្វាន់ពិសេស ឬសេចក្តីកោតសរសើរពីសាលា ពីក្រសួងអប់រំ យុវជន និងកីឡា ឬពីអង្គការណាឬទេ?

[ ] ខ្ញុំបានទទួល ________________________ (សូមភ្ជាប់នូវឯកសារឬរូបថតមកជាមួយ) [ ] ទេ ខ្ញុំមិនបានទទួលទេ

*634 Oakwood Court, Westbury, NY 11590* *EMail: Selecting@ceefoundation.org* *www.ceefoundation.org*


Rev9 – Oct. 12

**២៤.** ក្រៅពីការសិក្សាក្នុងថ្នាក់រៀន តើអ្នកដែលបានបំពេញកិច្ចការជាបន្ថែម ដូចជាកិច្ចការបម្រើសង្គមជាដើម ឬទេ **?**

(សូមបង្ហាញភស្តុតាង ដូចជា លិខិតបញ្ជាក់ ឬសំបុត្រសរសើរ ។ល។)

[ ] ខ្ញុំនៅក្នុងក្រុមអត្តពលិកនៃវិទ្យាល័យ

[ ] ខ្ញុំបានស្ម័គ្រចិត្តបម្រើសង្គមនៅ ______________________________

[ ] ខ្ញុំបាន(សូមសរសេរបញ្ជាក់) ______________________________

[ ] ទេ ខ្ញុំផ្ចង់ក្នុងការសិក្សាតែប៉ុណ្ណោះ

**២៥.** ខ្ញុំបានអាន ហើយយល់ច្បាស់អំពីលក្ខណៈវិនិច្ឆ័យ តម្រូវការ កំណត់ លក្ខ័ណ្ឌ រួមទាំងបេសកកម្ម គោលដៅ តម្លៃ និងទស្សនៈ នៃ មូលនិធិខ្មែរសម្រាប់ការសិក្សា (មខស) ដូចដែលបានពិពណ៌នានៅវិបសាយ Website នេះ៖ www.ceefoundation.org

[ ] បាទ/ចាស ខ្ញុំបានយល់ច្បាស់ ហើយខ្ញុំនឹងប្រតិបត្តិតាម [ ] ទេ ខ្ញុំមិនយល់ស្របទេ

យោលតាមការយល់របស់ខ្ញុំ ខ្ញុំសូមប្រកាសថា សេចក្តីដែលខ្ញុំសេសេរខាងលើ ពិតជាត្រឹមត្រូវ និងប្រាកដ។ ផ្ទុយទៅវិញបើបែរជា**មានការមិនពិតវិញនោះ** មខស អាចនឹងបញ្ឈប់អាហារូបករណ៍របស់ខ្ញុំ ហើយ**ខ្ញុំត្រូវសងប្រាក់**ដែលខ្ញុំបានទទួលទាំងប៉ុន្មាន ត្រឡប់ទៅ**មខស**វិញទាំងអស់។

[ ] ខ្ញុំយល់ព្រម [ ] ខ្ញុំមិនយល់ព្រម

ខ្ញុំយល់ព្រមឲ្យ **មខស** ដកស្រង់សេចក្តីសរសេររបស់ខ្ញុំ ដោយអន្លើ ឬទាំងអស់ យកទៅចុះផ្សាយនៅ វិបសាយ**មខស** ដើម្បីជាប្រយោជន៍ដល់អ្នកផ្តល់អាហារូបករណ៍ ឬជាដំណឹងផ្សេងៗ ដែល **មខស** យល់ថាត្រឹមត្រូវ។

[ ] ខ្ញុំយល់ព្រម [ ] ខ្ញុំមិនយល់ព្រម

ខ្ញុំយល់ព្រម និងធ្វើតាមទាំងអស់ បើខ្ញុំមិនបានក្បៀសប្រអប់(Box)ទាំង៣ខាងលើនេះទេ ខ្ញុំនឹងមិនអាច ទទួលអាហារូបករណ៍នេះបានទេ ។

**២៦.** ហត្ថលេខាសិស្សដាក់ពាក្យសុំ ____________________ កាលបរិច្ឆេទ ________________

អាចសរសេរបន្ថែមជាភាសាខ្មែរ បារាំង ឬ អង់គ្លេស នៅកន្លែងនេះ(សូមបញ្ជាក់ពីលេខសំនួរផងបើសិនជាមាន)

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

Rev9 – Oct. 12

មូលនិធិខ្មែរសម្រាប់ការសិក្សា

**CAMBODIAN EDUCATION EXCELLENCE FOUNDATION**

*634 Oakwood Court, Westbury, NY 11590* *EMail: Selecting@ceefoundation.org* *www.ceefoundation.org*

*ឯកសារពាក់ព័ន្ធសំរាប់ស្នើរសុំអាហារូបករណ៍ថ្មី:*

***Required Documents for New Applicant :***

[ ] រូបថតទំហំ 40mm x 60mm ឬ៤x៦ មួយសន្លឹក

[ ] ព្រឹត្តិប័ត្រពិន្ទុពីវិទ្យាល័យ / សញ្ញាប័ត្រ ទុតិយភូមិ( បាក់ឌុប )

[ ] លទ្ធផលប្រលងបញ្ចប់ឆ្នាំ ឬពិន្ទុតាមមុខវិជ្ជានីមួយៗនៅមហាវិទ្យាល័យ

[ ] ភស្តុតាងអនុញ្ញាតឲ្យចូលរៀននៅសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ ឬវិជ្ជាស្ថានណាមួយ

[ ] **បទនិពន្ធ** Essay **២០០០ពាក្យ** ( សូមអានការណែនាំនៅក្នុង**វែបសាយ**យើង នូវចំណុចដែលត្រូវសរសេរ )

[ ] **លិខិតគាំទ្រ** Support Letter **ចំនួន ៣ ច្បាប់** ( សូមអានការណែនាំនៅក្នុង**វែបសាយ**យើង នូវចំណុចដែលត្រូវសរសេរ )

[ ] ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណកូនសិស្ស ឬសៀវភៅគ្រួសារ

[ ] ឯកសារផ្សេងៗ, សូមបញ្ជាក់:.......................................

*ឯកសារពាក់ព័ន្ធសំរាប់ស្នើរសុំអាហារូបករណ៍ឡើងវិញ:*

***Required Documents for Renewal Applicant :***

[ ] រូបថតទំហំ 40mm x 60mm ឬ៤x៦ មួយសន្លឹក

[ ] លទ្ធផលប្រលង**បញ្ចប់ឆ្នាំ** ឬពិន្ទុតាមមុខវិជ្ជានីមួយៗ នៅមហាវិទ្យាល័យ ឬវិជ្ជាស្ថានណាមួយ

[ ] ភស្តុតាងអនុញ្ញាតឲ្យចូលរៀននៅសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ ឬវិជ្ជាស្ថានណាមួយ

[ ] **បទនិពន្ធ** Essay **២០០០ពាក្យ** ( សូមអានការណែនាំនៅក្នុង**វែបសាយ**យើង នូវចំណុចដែលត្រូវសរសេរ )

[ ] ព្រឹត្តិប័ត្រពិន្ទុពីវិទ្យាល័យ / ឬសញ្ញាប័ត្រ ទុតិយភូមិ( បាក់ឌុប )

[ ] ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណកូនសិស្ស

[ ] ឯកសារផ្សេងៗ, សូមបញ្ជាក់:.......................................